# សិក្ខាសាលាបណ្តុះបណ្តាល

ស្តីអំពី

# អភិបាលកិច្ចល្អ

# Good Governance

រៀបចំដោយ

**អង្គការលើកកំពស់ធនធានសហគមន៍ដើម្បីការអភិវឌ្ឍន៍**

កំពង់ចាម

ថ្ងៃទី 16 ខែ មករា ឆ្នាំ 2011

ដឹកនាំអង្គសិក្ខាសាលា :

លោក សែម សំអាន នាយកអង្គការ

ជំនួយការរៀបចំ :

កញ្ញា ម៉ៅ សុផល ប្រធានរដ្ឋបាល

កញ្ញា បូ ពុទ្ធា ជំនួយការ

កញ្ញា ស៊ុយ ណាវ៉ា បុគ្គលិក

លោក សែម សំអ៊ន់ បុគ្គលិក

# ១ ទស្សនទាននៃអភិបាលកិច្ច

## ១. ទស្សនទាននៃអភិបាលកិច្ច

អភិបាលកិច្ចល្អ ជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការជំរុញ និងគាំទ្រ ដំណើរការនៃការគ្រប់គ្រងធនធានរបស់ស្ថាប័ន អង្គភាព និងការអភិវឌ្ឍ មួយប្រកបដោយនិរន្តរភាព ។

*វគ្គបណ្តុះបណ្តាលនេះ* មានលក្ខណៈសាមញ្ញ ងាយយល់ និងងាយប្រើប្រាស់ ដែលក្នុងនោះបរិយាយអំពី : ១).ទិដ្ឋភាពទូទៅនៃអភិបាលកិច្ច ២).ការចូលរួម ៣).នីតិរដ្ឋ ៤).តម្លាភាព ៥).ការព្រមព្រៀង ឯកភាពគ្នា ៦).សមធម៌ ៧).ប្រសិទ្ធភាពខ្ពស់ ៨).គណនេយ្យភាព និង ៩).ការឆ្លើយតប ។

ភាពត្រឹមត្រូវតាមគោលនយោបាយ គឺជាល័ក្ខខ័ណ្ឌចាំបាច់ដំបូងគេបំផុតនៃអភិបាលកិច្ចល្អ ។ ភាពត្រឹមត្រូវតាមគោលនយោបាយ ត្រូវបានពិចារណាដោយផ្តោតជាសំខាន់ទៅលើ :

- ការគាំទ្រដោយប្រជាពលរដ្ឋភាគច្រើនបំផុត ឬទាំងអស់ និង
- ការបំរើផលប្រយោជន៍ដល់ប្រជាពលរដភាគច្រើនបំផុត ឬ ទាំងអស់ ។

## ២. និយមន័យ

**អភិបាលកិច្ច** ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាជាច្រើន អាស្រ័យនឹងស្ថានភាពជាក់ស្តែង ។ ជាសាមញ្ញ អភិបាលកិច្ច មានន័យថា :

- គឺជាវិធីសាស្ត្រដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រង សេដ្ឋកិច្ច សង្គមកិច្ច នីម្បីរើផលប្រយោជន៏រួមរបស់ ប្រជាពលរដ្ឋ ( *ឯកសារ អភិបាលកិច្ចល្អសំរាប់ក្រុមប្រឹក្សាឃុំសង្កាត់* ) ។

- *អភិបាលកិច្ចជាការប្រើប្រាស់អំណាចខាងនយោបាយសេដ្ឋកិច្ច និងរដ្ឋបាល ដើម្បីគ្រប់គ្រងកិច្ចការរបស់ប្រទេស ( ឯកសារ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ UNDP ) ។*

-*អភិបាលកិច្ច គឺជាការអនុវត្តសិទ្ធិនយោបាយ សេដ្ឋកិច្ច រដ្ឋបាល ឬអ្វីផ្សេងៗដើម្បីគ្រប់គ្រងកិច្ចការ និងធនធានរបស់ប្រទេសមួយ ដោយក្នុងនោះមានទាំងការរៀបចំឲ្យមានយន្តការ ដំណើរការផ្សេងៗ ដើម្បីឲ្យប្រជាពលរដ្ឋ និងក្រុមផ្សេងៗអាចទាមទារនូវផលប្រយោជន៍របស់ពួកគាត់ ការអនុវត្តសិទ្ធិស្រប ច្បាប់របស់គាត់ ស្របនិងកាតព្វកិច្ចរបស់គាត់ ព្រមទាំងសម្រុះសម្រួលការខ្វែងគំនិតរបស់គាត់។ ( ឯកសារ អង្គការ STAR KAMPUCHEA 2010 ) ។*

## ៣ គោលបំណងនៃអភិបាលកិច្ច

គោលបំណងនៃអភិបាលកិច្ច គឺដើម្បីគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និងវិបត្តិទាំងឡាយ តាមមធ្យោបាយមួយដែលផ្តល់នូវផលប្រយោជន៍យ៉ាងច្រើនបំផុតដល់ប្រជាពលរដ្ឋ ។

ដើម្បីសំរេចបាននូវគោលបំណងខាងលើនេះ គេបានទទួលស្គាល់ជាទូទៅថា **អភិបាលកិច្ច** ទាមទារនូវ**ការអភិវឌ្ឍធនធានមនុស្សប្រកបដោយនិរន្តរភាព** ។ ចំណុចសំខាន់ៗនៃការអភិវឌ្ឍធនធានមនុស្សប្រកប ដោយនិរន្តរភាពមានដូចខាងក្រោម :

- ត្រូវមានសេវាថៃទាំសុខភាពល្អសមស្រប និងគ្រប់គ្រាន់សំរាប់ ប្រជាពលរដ្ឋទាំងអស់ ដើម្បីជួយឱ្យពួកគេមានសុខ ភាពមាំមួន និងអាយុយឺនយូរ ។ នេះជាកត្តាដែលអាចធ្វើអោយប្រជាពលរដ្ឋ មានសុខុមាលភាព និង ថាមពលគ្រប់គ្រាន់ ដើម្បីចូលរួមបាន យ៉ាងពេញលេញនៅក្នុងសកម្មភាពសេដ្ឋកិច្ច និង សង្គម ។
- *ត្រូវមានសេវាអប់រំល្អសមស្រប និងគ្រប់គ្រាន់សំរាប់ប្រជាពលរដ្ឋទូទៅ ដើម្បីអោយពួកគេមានចំណេះដឹង និងជំនាញពេញលេញក្នុងការបង្កើតឪកាសអោយបានច្រើន និងសមស្របបំផុតសំរាប់ខ្លួនគេ ។*
- ត្រូវបង្កើតឱកាសសំរាប់ប្រជាពលរដ្ឋទូទៅ ដើម្បីទទួលបាននូវផលប្រយោជន៍ពីសកម្មភាពសេដ្ឋកិច្ច និងមានការងារធ្វើ ដើម្បីរកបានប្រាក់ចំណូលគ្រប់គ្រាន់សំរាប់បំពេញតម្រូវការជាមូលដ្ឋាន ដូចជា ស្បៀងអាហារ សំលៀកបំពាក់ ជំរកជាដើម សំរាប់ពួកគេផ្ទាល់ និងក្រុមគ្រួសាររបស់ពួកគេ ។

ចំណុចសំខាន់ទាំងពាខាងលើនេះ ត្រូវបានអនុវត្តតាមមធ្យោបាយ ដែលធានាបាននូវការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការថែរក្សាបរិស្ថាន ។

## ៤. តួអង្គសំខាន់ៗក្នុងអភិបាលកិច្ច

កាលពីមុនគេយល់ឃើញថា មានតែរដាភិបាលមួយគត់ ដែលជាតួអង្គនៃអភិបាលកិច្ច ។ ប៉ុន្តែបច្ចុប្បន្ននេះមានគំនិតថ្មីៗជាច្រើនបានបង្ហាញឱ្យ ឃើញថា ផ្នែកឯកជន និងអង្គការសង្គមស៊ីវិលផ្សេងៗទៀត ក៏បានដើរ តួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងសង្គមកិច្ចរបស់ប្រទេសផងដែរ ។ ដូចនេះតួអង្គសំខាន់ក្នុងអភិបាលកិច្ចមាន **បី** គឺ:

រដ្ឋាភិបាល ( ជាតួអង្គសំខាន់ជាងគេ)

ផ្នែកឯកជន

សង្គមស៊ីវិល




ឥទ្ធិពលនៃតួអង្គផ្នែកឯកជន និង សង្គមស៊ីវិល មានភាពខុសគ្នាពី ប្រទេសមួយទៅប្រទេសមួយ អាស្រ័យលើល័ក្ខខ័ណ្ឌមួយចំនួនដូចជា ប្រព័ន្ធនយោបាយ លក្ខណៈអំណោយផលខាងធនធានធម្មជាតិ ប្រជាពលរដ្ឋ ទីតាំងភូមិសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងកំរិតនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច . . . ។ល។

ជាក់ស្តែង នៅក្នុងប្រទេសខ្លះ ផ្នែកឯកជន និងសង្គមស៊ីវិល មានអំណាច និងវិសាលភាពយ៉ាងធំធេង ប៉ុន្តែប្រទេសមួយចំនួនផ្សេងទៀតផ្នែកឯកជន និងសង្គមស៊ីវិលនេះ មានអំណាច ឱកាស និងឥទ្ធិពលតិចតួចទៅលើកិច្ចការប្រទេសជាតិ ។

# ២ អភិបាលកិច្ចល្អ

## ១. និយមន័យអភិបាលកិច្ចល្អ

- អភិបាលកិច្ចល្អ មានន័យថា មានសមត្ថភាពគ្រប់គ្រងកិច្ចការ និងធនធានរបស់ប្រទេសជាតិប្រកបដោយឆន្ទៈ មានលក្ខណៈបើកចំហរ តម្លាភាព គណនេយ្យភាព សមធម៌ ឆ្លើយតបតម្រូវការ និង ការចូល រួមរបស់ប្រជាពលរដ្ឋ ( ឯកសារអង្គការ STAR KAMPUCHEA 2010 ) ។

- អភិបាលកិច្ចល្អ ជាវិធីសាស្ត្រ ឬមធ្យោបាយដែលរដ្ឋ ស្ថាប័ន អង្គភាព ប្រើប្រាស់ក្នុងការគ្រប់គ្រងសេដ្ឋកិច្ច សង្គមកិច្ច និង សន្តិសុខ ដើម្បីបំរើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ ( ឯកសារអភិបាលកិច្ចល្អសំរាប់ក្រុមប្រឹក្សាឃុំសង្កាត់ ) ។

## ២. គោលការណ៍អភិបាលកិច្ចល្អ

គំនិតទូទៅនៃគោលការណ៍របស់អភិបាលកិច្ចល្អ ផ្តោតលើចំនុចដូចខាងក្រោម ៖

- ផ្តោតលើគោលបំណងរបស់អង្គភាព និងការជះឥទ្ធិពលដល់ប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់សេវាកម្ម ។
- ការអនុវត្តប្រកបដោយប្រសិទ្ធភាពទៅតាមមុខងារ និងតួនាទីដែលបានកំណត់ច្បាស់លាស់ ។
- ការលើកស្ទួយគុណតំលៃរបស់អង្គភាពទាំងមូល ដែលស្តែងឡើងតាមរយៈការប្រព្រឹត្ត ។
- ការផ្តល់នូវការជូនដំណឹងអំពីសេចក្តីសំរេចចិត្ត និងការគ្រប់គ្រងហានិភ័យប្រកបដោយតម្លាភាព
- ការបង្កើនសមត្ថភាព និងលទ្ធភាពរបស់អ្នកគ្រប់គ្រង ដើម្បីគ្រប់គ្រងអោយមានប្រសិទ្ធភាព
- ការកៀងគរអ្នកពាក់ព័ន្ធនានា និងធ្វើអោយមានគណនេយ្យភាពពិតប្រាកដ ។

គោលការណ៍របស់អភិបាលកិច្ចល្អ ជាជំរស់មាន៨ចំនុច ៖

១. តម្លាភាព
២. នីតិរដ្ឋ
៣. ការព្រមព្រៀងឯកភាពគ្នា
៤. សមធម៌
៥. ប្រសិទ្ធភាពខ្ពស់
៦. ការឆ្លើយតប
៧. គណនេយ្យភាព
៨. ការចូលរួម






## ក. ការចូលរួម

ការចូលរួមក្នុងបរិបទអភិបាលកិច្ចល្អ សំដៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំងបុរស និងស្ត្រីក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្ត និង អនុវត្តសេចក្តីសំរេចចិត្តនោះ។

សារៈសំខាន់នៃការចូលរួម គឺដើម្បីធានាថាព័ត៌មានទាំងឡាយស្តីពីបញ្ហា តម្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋគ្រប់រូប ត្រូវបានប្រមូល និងវិភាគបានគ្រប់ជ្រុងជ្រោយ មុននឹងធ្វើការសំរេចចិត្ត។

ជាទូទៅការចូលរួមធ្វើឡើងតាម ២របៀប គឺការចូលរួមដោយផ្ទាល់ និងការចូលរួមតាមរយៈអ្នកតំណាង។

### ១. ការចូលរួមដោយផ្ទាល់

ការចូលរួមដោយផ្ទាល់មានន័យថា ជាការចូលរួមរបស់អ្នកពាក់ព័ន្ធគ្រប់រូបដោយខ្លួនឯងផ្ទាល់នៅក្នុងដំណើរនៃការធ្វើការសំរេចចិត្ត និងការអនុវត្តសេចក្តីសំរេចចិត្តនោះ។

### ២. ការចូលរួមតាមរយៈអ្នកតំណាង

ការចូលរួមតាមរយៈអ្នកតំណាងមានន័យថា អ្នកតំណាងរបស់ប្រជាពលរដ្ឋចូលរួមក្នុងដំណើរការនៃការសំរេចចិត្ត និងអនុវត្តសេចក្តីសំរេចចិត្តនោះ។

អ្នកតំណាងត្រូវតែបំពេញតួនាទីជាអ្នកតំណាងឲ្យឆន្ទៈ និងផលប្រយោជន៍ប្រជាពលរដ្ឋដែលខ្លួនតំណាងឲ្យ។

អ្នកតំណាងប្រជាពលរដ្ឋ អាចត្រូវបានគេជ្រើសរើសតាមនីតិវិធីផ្សេងៗទៅតាមលក្ខណៈ និងស្ថានភាពជាក់ស្តែងដូចជា ៖

- ការតែងតាំង
- ការព្រមព្រៀងឯកភាពគ្នា
- ការបោះឆ្នោត
- ទំនៀមទំលាប់ប្រពៃណី
- ........។ល។

ខាងក្រោមនេះ គឺជាអ្នកតំណាងរបស់ប្រជាពលរដ្ឋដែលចូលរួម នៅក្នុងសកម្មភាពអភិវឌ្ឍឃុំ សង្កាត់ដូចជា ៖

- ក្រុមប្រឹក្សាឃុំ សង្កាត់
- គណៈកម្មាធិការកសាងផែនការ និង ថវិកា
- គណៈកម្មការលទ្ធកម្ម
- គណៈកម្មកាគ្រប់គ្រងគំរោង
- គណៈកម្មាធិការទទួលបន្ទុកកិច្ចកាតនារី និងកុមារ
- ក្រុមប្រើប្រាស់ និងថែទាំលទ្ធផលគំរោង
- គណៈកម្មការធនធានធម្មជាតិ
- អង្គការសហគមនិមូលដ្ឋាន
- ........។ល។

ក្នុងការជ្រើសរើសអ្នកតំណាង ត្រូវពិចារណាចំណុចមួយចំនួនដូចខាងក្រោម ៖

- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយមានសមត្ថភាព និងលទ្ធភាពអាចបំពេញតួនាទីជាអ្នកតំណាងបាន។
- ជាតំណាងពិតប្រាកដឲ្យក្រុមប្រឹក្សាជាក់លាក់ណាមួយ
- ជ្រើសរើស ឬតែងតាំងអ្នកតំណាងទៅតាមនីតិវិធីដែលសមស្របទៅនិងស្ថានភាពជាក់ស្តែង ។
- កំណត់តួនាទី និងការទទួលខុសត្រូវឲ្យបានច្បាស់លាស់
- មានផែនការការងារច្បាស់លាស់
- មាននីតិវិធីផ្លាស់ប្តូរសមាជិកអ្នកតំនាងច្បាស់លាស់
- មានកម្មវិធីពង្រឹងសមត្ថភាព និងការគាំទ្រជាប្រចាំដល់អ្នកតំណាង

៣. វិធីសាស្ត្រដើម្បីជំរុញការចូលរួម

ដើម្បីជំរុញឲ្យសកម្មភាពចូលរួមកាន់តែមានភាពងាយស្រួលឡើង និងដើម្បីធានាឲ្យប្រជាពលរដ្ឋ និងអ្នកតំណាងរបស់ប្រជាពលរដ្ឋ មានឱកាសចូលរួមពេញលេញ ជាពិសេសតំណាងក្រុមអ្នកក្រីក្រ និងក្រុមងាយរងគ្រោះ ក្រុមប្រឹក្សាឃុំ សង្កាត់គួរពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម ៖

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីសារៈសំខាន់ និងភាពចាំបាច់នៃការចូលរួមរបស់ពួកគេ
- ផ្សព្វផ្សាយព័ត៌មានស្ដីអំពីកិច្ចប្រជុំនិងព័ត៌មានផ្សេងៗ ឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ
- កំណត់ពេលវេលា និងទីកន្លែងប្រជុំឲ្យបានសមស្រប
- បង្កបរិយាកាសនៃការប្រជុំឲ្យមានលក្ខណៈជាចំហរ មានការចូលរួមយ៉ាងផុលផុស និងសប្បាយរីករាយ
- រៀបចំទីកន្លែងប្រជុំប្រកបដោយផាសុកភាព
- រៀបចំឲ្យមានប្រព័ន្ធទទួល និងផ្ដល់ព័ត៌មានដែលមានលក្ខណៈងាយៗ និងអាចទទួលយកបាន
- បង្កើតទំនាក់ទំនងល្អ និងស្និតស្នាលជាមួយប្រជាពលរដ្ឋ

**ខ. នីតិរដ្ឋ**

នីតិរដ្ឋក្នុងន័យអភិបាលកិច្ចល្អ ទាមទារឲ្យមានឯកសារក្របខណ្ឌច្បាប់គ្រប់គ្រាន់ ដើម្បីបំរើនិងការពារផលប្រយោជន៍សាធារណៈ ហើយច្បាប់ទាំងនោះត្រូវបានអនុវត្តដោយមិនលំអៀង។ លើសពីនេះទៀត ច្បាប់ទាំងនោះត្រូវតែមានការការពារសិទ្ធិមនុស្ស ជាពិសេសក្រុមងាយរងគ្រោះ ឬ ក្រុមភាគតិច។

ដូច្នេះត្រូវមានប្រព័ន្ធតុលាការឯករាជ្យ និងយុត្តិធម៌ និងសមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀង និងមិនពុករលួយ។

នីតិរដ្ឋក្នុងន័យអភិបាលកិច្ចល្អផ្ដោតជាសំខាន់ទៅលើ ៖

- ឯកសារក្របខ័ណ្ឌច្បាប់
- ការអនុវត្តច្បាប់ដោយមិនលំអៀង
- ការការពារសិទ្ធិមនុស្ស
- តុលាការឯករាជ្យ និងយុត្តិធម៌
- សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់ដោយមិនលំអៀង និង មិនពុករលួយ

១. ឯកសារក្របខ័ណ្ឌច្បាប់

ឯកសារក្របខ័ណ្ឌច្បាប់ គឺជាលិខិតបទដ្ឋានគតិយុត្តិដែលរួមមាន ច្បាប់ អនុក្រឹត្យ ប្រកាស សេចក្តីសំរេច សេចក្តីណែនាំ ដីកា និងលិខិតបទដ្ឋាននានា ។

ឯកសារក្របខ័ណ្ឌច្បាប់មួយចំនួន ដែលទាក់ទងនឹងការបំពេញការងាររបស់ក្រុមប្រឹក្សាឃុំសង្កាត់ រួមមាន ៖

- ច្បាប់ស្តីពីការគ្រប់គ្រងអង្គភាព
- អនុក្រឹត្យស្តីពីមូលនិធិ
- ប្រកាសស្តីពីការកសាងផែនការអភិវឌ្ឍន៍
- ...............។ល។

**២. ការអនុវត្តច្បាប់ដោយមិនលំអៀង**

ឯកសារក្របខ័ណ្ឌច្បាប់ត្រូវបានដាក់ឲ្យប្រើប្រាស់ជាបន្តបន្ទាប់ ។ រាល់ការអនុវត្តត្រូវតែធ្វើឡើងដោយស្រមតាមឯកសារក្របខ័ណ្ឌច្បាប់ទាំងនោះយ៉ាងពេញលេញត្រឹមត្រូវ យុត្តិធម៌និងមិនលំអៀង។

ឧទាហរណ៍ ៖ ការតែងតាំងសមាជិកគណៈកម្មការនានា ការជ្រើសរើសទីតាំងគំរោង ការអនុវត្តគំរោងឃុំ សង្កាត់ជាដើម ត្រូវតែធ្វើឡើយទៅតាមគោលការណ៍ណែនាំ ដែលបានកំណត់ ។

**៣. ការការពារសិទ្ធិមនុស្ស**

សិទ្ធិមនុស្ស គឺជាសេចក្តីត្រូវការចាំបាច់របស់មនុស្សគ្រប់រូប ដែលមានតាំងពីកំណើតដើម្បីទាមទារនូវអ្វីៗ ដែលឬធ្វើឲ្យមនុស្សរស់នៅប្រកបដោយវិចារណញ្ញាណ និងសេចក្តីថ្លៃថ្នូរ ។

**៤. តុលាការឯករាជ និងយុត្តិធមិ៍**

ជាទូទៅក្រុមប្រឹក្សាឃុំ សង្កាត់តែងតែប្រឈមមុខនឹងបញ្ហា ឬជម្លោះនានាដែលកើតឡើងក្នុងមូលដ្ឋានរបស់ខ្លួន។ បញ្ហាទាំងនោះមានដូចជា ជម្លោះដីធ្លី អំពើហឹង្សាក្នុងគ្រួសារ និងបញ្ហាឬជម្លោះជាច្រើនរូបផ្សេងទៀត។

ក្រុមប្រឹក្សាឃុំ សង្កាត់ ជាអ្នកចូលរួមសម្រុះសម្រួលនូវរាល់បញ្ហាជម្លោះនោះដំបូងគេ។ បើករណីជម្លោះនោះមិនអាចសម្រុះសម្រួលបានករណីជម្លោះនោះត្រូវដោះស្រាយតាមនីតិវិធីតុលាការ។

តុលាការមានតួនាទីកាត់ក្តីជម្លោះនោះ ដោយយុត្តិធមិ៍ និងមិនលំអៀង។ ដូច្នោះតុលាការឯករាជ្យ និងយុត្តិធមិ៍ ជាយន្តការស្នូលមួយក្នុងការជំរុញឲ្យមានការគោរពនិងអនុវត្តច្បាប់។

**៥. សមត្ថកិច្ចពង្រឹងការអនុវត្តច្បាប់មិនលំអៀង និងមិនពុករលួយ**

ជាការពិតណាស់ ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីត្រឹមតែធ្វើការសម្រុះសម្រួល និងរាយការណ៍ទៅសមត្ថកិច្ចទទួលខុសត្រូវអំពីបញ្ហា ឬជម្លោះដែលកើតឡើង។ សមត្ថកិច្ចទទួលខុសត្រូវ

ត្រូវអនុវត្តតាមច្បាប់ដោយមិនលំអៀង និងមិនពុករលួយ គឺជាការរួមចំណែកយ៉ាងខ្លាំងក្នុងអភិបាលកិច្ចល្អ។

**គ. តម្លាភាព**

តម្លាភាពក្នុងន័យអភិបាលកិច្ចល្អ មានន័យថារាល់ការសំរេចចិត្ត និងការអនុវត្តសេចក្តីសំរេចនោះត្រូវធ្វើឡើង ៖

- ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិនានា
- ព័ត៌មានពាក់ព័ន្ធនឹងការសំរេចចិត្ត និងការអនុវត្តសេចក្តីសំរេចចិត្តត្រូវផ្សព្វផ្សាយជាចំហ តាមរយៈប្រព័ន្ធសមស្រប និងអាចស្វែងរកបាន ជាពិសេសចំពោះអ្នកដែលទទួលនូវ ផលប៉ះពាល់ពីការសំរេចចិត្ត និងការអនុវត្តសេចក្តីសំរេចចិត្តទាំងនោះ។
- ព័ត៌មានទាំងនោះត្រូវមានលក្ខណៈគ្រប់គ្រាន់ និងងាយយល់។

ឧទាហរណ៍១ ៖ រាល់ការធ្វើសេចក្តីសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុលោមតាមបទបញ្ជាផ្ទៃក្នុង ដូចជា ៖

- ប្រជុំយ៉ាងតិចក្នុង១ខែ និងអាចមានការប្រជុំពិសេសថែមទៀត
- រាល់កិច្ចប្រជុំ ត្រូវធ្វើឡើងជាសាធារណៈ
- សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានអញ្ជើញរយៈពេល ៣ថ្ងៃមុនពេលប្រជុំ
- កម្មវិធីប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្សព្វផ្សាយជាសាធារណៈ ដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់របស់ខ្លួន។
- របៀបវារៈប្រជុំ ត្រូវបានរៀបចំជាលាយលក្ខណ៍អក្សរ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋអាចស្នើសុំបន្ថែមចំណុចផ្សេងៗ ទៅក្នុងរបៀបវារៈនេះ។
- ស្មៀនឃុំ សង្កាត់ និងអ្នកចូលរួមផ្សេងៗទៀតដែលលមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិបញ្ចេញមតិដោយសេរីប៉ុន្តែពុំមានសិទ្ធិសំរេចនោះទេ។
- រាល់ការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្អែកតាមមតិភាគច្រើនជាដាច់ខាត។
- រាល់ការសំរេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវកត់ត្រានៅក្នុងកំណត់ហេតុប្រជុំ និងត្រូវផ្សព្វផ្សាយជាសាធារណៈ។

ឧទាហរណ៍២ ៖ កិច្ចលទ្ធកម្មគំរោងមូលនិធិឃុំ សង្កាតើត្រូវធ្វើឡើងតាមនិតិវិធីដែលមានចែងនៅក្នុងសៀវភៅណែនាំ ស្តីពីការអនុវត្តគំរោងមូលនិធិឃុំ សង្កាត់ដូចជា ៖

- គណៈកម្មការលទ្ធកម្ម ត្រូវបានកើតឡើង និងបំពេញមុខងារស្របតាមការណែនាំ
- ឯកសារពាក់ព័ន្ធនឹងការដេញថ្លៃ ត្រូវផ្សព្វផ្សាយជាសាធារណៈ
- កិច្ចប្រជុំលទ្ធកម្ម ត្រូវរៀបចំឡើងជាសាធារណៈ

- លទ្ធផលនៃការដេញថ្លៃ ត្រូវប្រកាសជាសាធារណៈ

ឧទាហរណ៍៣ ៖ ការប្រើប្រាស់ថវិការមូលនិធិឃុំ សង្កាត់ ត្រូវអនុវត្តទៅតាមគោលការណ៍ណែនាំ ដូចជា ៖

- ត្រូវរៀបចំគំរោងថវិកាប្រចាំឆ្នាំ ដោយមានការចូលរួម
- ត្រូវអនុវត្តចំណាយ ចំនូលទៅតាមនីតិវិធីដែលបានកំនត់
- ត្រូវចុះបញ្ជីការគណនេយ្យឲ្យបានច្បាស់លាស់
- ត្រូវធ្វើការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុជាសាធារណៈ

**ឃ. ការព្រមព្រៀងឯកភាពគ្នា**

ការព្រមព្រៀងឯកភាពគ្នា ក្នុងន័យអភិបាលកិច្ចល្អ គឺជាការពិចារណាទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍ និងតម្រូវការរបស់អ្នកពាក់ព័ន្ធផ្សេងៗគ្នានៅក្នុងសង្គម ហើយឈានទៅរកការសំរេចចិត្តដោយមានការព្រមព្រៀងឯកភាពគ្នាលើជំរើស និងវិធីសាស្រ្តណាមួយដែលបំរើផលប្រយោជន៍រួម សំរាប់សហគមន៍ទាំងមូល។

១. ភាពផ្សេងៗគ្នានៅក្នុងសង្គម

ក្រុមមនុស្សនៅក្នុងសង្គមតែងតែមានគំនិត បញ្ហាតម្រូវការអាទិភាពដំណោះស្រាយ ការពេញចិត្តចំណេះដឹង និងការយល់ឃើញផ្សេងៗគ្នា។ ហេតុដូចនេះ ការពិចារណាឲ្យបានយ៉ាងទូលំទូលាយ និងវែងឆ្ងាយលើផលប្រយោជន៍នៃការពាក់ព័ន្ធផ្សេងៗគ្នាទាំងនោះ ត្រូវតែគិតដល់ចំណុចមួយចំនួនដូចជា ៖

- **ស្ថានភាព** រួមមានដូចជា បញ្ហា តម្រូវការ អាទិភាព ភេទ អាយុ ឋានៈក្នុងសង្គមមុខរបរ.......។ល។
- **ក្រុមជនរងគ្រោះ** រួមមានដូចជា អ្នកជំងឺអេដស៍ ជនពិការ អ្នកប្រើប្រាស់គ្រឿងញៀន កុមារកំព្រា ស្ត្រីរកស៊ីផ្លូវភេទ ទុរគតជន ចាស់ជរា.......។ល។
- **ប្រវត្តិសាស្រ្ត** ប្រវត្តិរបស់ក្រុម ឬជនជាតិនីមួយៗ
- **វប្បធម៌ ទំនៀមទំលាប់ប្រពៃណី** ដូចជា ភាសា ពិធីអាពាហ៍ពិពាហ៍ ពិធីបុណ្យប្រពៃណីផ្សេងៗទៀត........។ល។
- **ជំនឿ សាសនា** ដូចជា សាសនាព្រះពុទ្ធ សាសនាឥស្លាម សាសនាគ្រិស្ត.....។ល។
- **គណបក្សនយោបាយ** ដូចជា គណបក្សប្រជាជន ហ្វ៊ុនស៊ិនប៉ិច សមរង្ស៊ី..........។ល។
- **ក្រុមជាតិសាសន៍** ដូចជា គួយ ភ្នង ចារាយ គ្រឹង កាចក់ ចិន ចាម វៀតណាម....។ល។

២. គោលការណ៍ណែនាំសំរាប់សំរបសំរួលឲ្យមានការព្រមព្រៀងឯកភាពគ្នា

ក. លក្ខខ័ណ្ឌនៃការព្រមព្រៀងឯកភាពគ្នា រួមមាន

- កាព្រមព្រៀងគ្នាប្រកបដោយសុខដុមរមនា

- ការពិគ្រោះយោបល់ជាមួយក្រុមពាក់ព័ន្ធទាំងអស់
- ការចូលរួមពីក្រុមអ្នកពាក់ព័ន្ធផ្សេងៗក្នុងដំណើរការនៃការធ្វើសេចក្ដីសំរេចចិត្ត
- ការយល់ដឹងអំពីគ្នាទៅវិញទៅមករវាងក្រុមពាក់ព័ន្ធទាំងអស់

**ខ. ដំណើរការនៃការព្រមព្រៀងឯកគ្នា**

ខាងក្រោមនេះជាការណែនាំខ្លះៗ ដើម្បីធ្វើការសំរបសំរួលឲ្យមានការព្រមព្រៀងឯកភាពគ្នា

- រៀបចំឲ្យមានការជួបជុំគ្នារវាងក្រុមពាក់ព័ន្ធទាំងអស់
- ស្វែងយល់គ្នាទៅវិញទៅមករវាងក្រុមអ្នកពាក់ព័ន្ធទាំងអស់និង បង្កើតការយោគយល់គ្នា
- ពិភាក្សាជាមួយក្រុមពាក់ព័ន្ធទាំងអស់ អំពីផលប្រយោជន៏ និងបង្កើតជំរើសនានា
- សំរុះសំរួលដើម្បីសំរេចយកជំរើសល្អមួយដែលបំរើនូវផលប្រយោជន៏រួមដោយមានការព្រមព្រៀងឯកភាពគ្នា ប្រកបដោយសុខដុមរមនា។

## ង. សមធម៌

សមធម៌ក្នុងន័យអភិបាលកិច្ចល្អ មានន័យថាក្រុម ឬជនគ្រប់រូបទាំងអស់នៅក្នុងសហគមន៍ ជាពិសេសក្រុមភាគតិច និងក្រុមដែលងាយរងគ្រោះមានឱកាសគ្រប់គ្រាន់ ក្នុងការចូលរួមបញ្ចេញយោបល់ លើកឡើងនូវតម្រូវការពិត អនុវត្តសកម្មភាព និងទទួលផលប្រយោជន៍សមស្របដើម្បីកែលំអ និងថែរក្សាសុខុមាលភាពរបស់ពួកគេ។ លើសពីនេះទៀតពួកគេមានអារម្មណ៍ ថាខ្លួនគឺជាសមាជិកពិតប្រាកដរបស់សង្គម និងមិនត្រូវបានបោះចោលនោះទេ។

សុខមាលភាពរបស់សមាជិក ឬក្រុមនីមួយៗគឺជាសុខុមាលភាពរបស់សង្គមទាំងមូល។ ដូចនេះដំណើរការនៃការសំរេចចិត្ត និងការអនុវត្តសេចក្ដីសំរេចចិត្តប្រកបដោយសមធម៌ និងធ្វើឲ្យសមាជិកទាំងអស់នៅក្នុងសង្គមមានអារម្មណ៍ថា ពួកគេម្នាក់ៗគឺជាសមាជិកពិតប្រាកដរបស់សង្គម និងបានចូលរួមចំណែក នៅក្នុងដំណើរការអភិវឌ្ឍសង្គមនោះ ។ លើសពីនេះទៅទៀតមិនមានសមាជិកណាម្នាក់គិតថាខ្លួនគេត្រូវបានសង្គមបោះបង់ចោលឡើយ។

សុខមាលភាពផ្ដោតសំខាន់ទៅលើភាពសប្បាយ ភាពសុខស្រួល សុវត្ថិភាព សន្តិសុខ សុខភាពល្អ......។ល។ សុខុមាលភាពរបស់មនុស្សម្នាក់ៗ មិនគ្រាន់តែគិតលើផ្នែករូបរាងកាយប៉ុនោះទេ តែត្រូវគិតដល់ផ្នែកជំនឿសាសនា ស្មារតី ផ្លូវចិត្ត អារម្មណ៍ ព្រមទាំងភាពគ្រប់គ្រាន់ក្នុងជីវភាពរស់នៅផងដែរ។

ជាក់ស្តែងដើម្បីធានាឲ្យមាន សមធម៌ នៅក្នុងការងារអភិវឌ្ឍឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ បាន៖

- o បង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និង កុមារ
- o បង្កើតអ្នកទទួលបន្ទុកការងារស្ត្រី និងកុមារ

- បង្កើតគណៈកម្មាធិការកសាងផែនការ និងថវិការ
- អនុញ្ញាតឲ្យតំណាងជនជាតិដើមភាគតិច ចូលរួមនៅក្នុងការប្រជុំគណៈកម្មាធិការ កសាង ផែនការ និងថវិកា
- ............។ល។

## ច. ប្រសិទ្ធភាពខ្ពស់

ប្រសិទ្ធភាពខ្ពស់ក្នុងន័យអភិបាលកិច្ចល្អ មានន័យថា ជាដំណើរការ និងរចនាសម្ពន្ធ័គ្រប់គ្រង ក្នុងការប្រើប្រាស់ធនធានឲ្យអស់លទ្ធភាព និងសន្សំសំចៃខ្ពស់ ដើម្បីបង្កើតលទ្ធផលដែលមានគុណភាពខ្ពស់ បរិមាណច្រើនអាចបំរើផលប្រយោជន៏ជាអតិបរមា និង បានឆ្លើយតបទៅនឹង តម្រូវការពិតរបស់សង្គម។ គោលគំនិតនៃប្រសិទ្ធភាពខ្ពស់ នៅក្នុងបរិបទអភិបាលកិច្ចល្អក៏បាន បញ្ចូលផងដែរ ចំពោះការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយនិរន្តភាព និងការការពារបរិស្ថាន។

ដើម្បីឲ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិចារណាលើចំនុចដូចខាងក្រោម ៖

- ការប្រើប្រាស់ធនធានឲ្យបានត្រឹមត្រូវ
- ការអនុវត្តន៍សកម្មភាពដែលជាអាទិភាពខ្ពស់
- ជៀសវាងការអនុវត្តន៍នូវការិយាធិបតេយ្យ
- ការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិ
- គ្មានអំពើពុករលួយ
- ការសំរេចចិត្តតាមបែបវិមជ្ឈការ
- ...............។ល។

### ១. ការប្រើប្រាស់ធនធានបានត្រឹមត្រូវ

កាលណាប្រើប្រាស់ធនធានបានត្រឹមត្រូវ នាំឲ្យមានប្រសិទ្ធភាពខ្ពស់។ ធនធានទាំងនោះមានដូចជា ធនធានមនុស្ស ធនធានថវិកា សម្ភារៈ ពេលវេលា.........។ល។

ឧទាហរណ៍ ១ ៖ ការរៀបចំបុគ្គលិកតាមជំនាញរបស់គេ គឺជាការប្រើប្រាស់ធនធានមនុស្សបានត្រឹមត្រូវនិងអាចមានប្រសិទ្ធភាពខ្ពស់ ព្រោះកាលណាបុគ្គលិកធ្វើការចំជំនាញរបស់គេនោះគេអាចធ្វើការបានល្អត្រឹមត្រូវ និងបានរហ័សទៀតបានផង។ ទន្ទឹមនោះចំណេះដឹងរបស់គេនិងមានការរីកចំរើនកាន់តែខ្លាំង ។

ឧទាហរណ៍ ២ ៖ ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវការទិញម៉ាស៊ីនភ្លើងមួយគ្រឿងសំរាប់ប្រើក្នុងការិយាល័យ នោះការគិតជាចំបងមិនគ្រាន់តែលើតម្លៃម៉ាស៊ីនភ្លើងប៉ុណ្ណោះទេ តែកំរិត

នៃការស៊ីប្រែងភាពអាចរកបាននូវគ្រឿងបន្លាស់ និងតម្លៃថែទាំក៏ជាចំណុចដែលត្រូវពិចារណាជា ចាំបាច់ផងដែរ។

**២. ការអនុវត្តសកម្មភាពដែលជាអាទិភាពខ្ពស់**

ការអនុវត្តន៍សកម្មភាពដែលជាអាទិភាពខ្ពស់ មានន័យថារាល់តម្រូវការពិតប្រាកដ ចាំបាច់ និងបន្ទាន់បំផុតរបស់ប្រជាពលរដ្ឋទូទៅត្រូវបានយកមកពិចារណា និងដោះស្រាយមុនគេ។

ប្រសិនបើគំរោងដែលជាអាទិភាពខ្ពស់របស់អាទិភាពខ្ពស់របស់អ្នកភូមិ ត្រូវបានអនុវត្តនោះ អ្នកភូមិនឹងចូលរួមក្នុងការអនុវត្តគំរោងនោះ ហើយមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការថែទាំសមិទ្ធិផលទាំងអស់នោះទៀតផង។ លើសពីនេះទៀតអ្នកភូមិនឹងមិនពេញបង់ទុនចូលរួម ព្រោះគំរោងនេះបានឆ្លើយតបទៅ នឹងតម្រូវការពិតប្រាកដរបស់ពួកគេ។

**៣. ជៀសវាងអនុវត្តការិយាធិបតេយ្យ**

ដើម្បីអោយការអនុវត្តន៍សកម្មភាពមានប្រសិទ្ធភាពខ្ពស់ ត្រូវជៀសវាងនូវការិយាធិបតេយ្យ ព្រោះបើមិនដូច្នេះទេ មានសកម្មភាពជាច្រើនតែងតែពន្យាជាបន្តបន្ទាប់ ដោយសារតែទំរង់បែបបទ ច្រើនពេក រង់ចាំការពិនិត្យឯកសារ និងការអនុម័តយល់ព្រមរបស់អ្នកដឹកនាំពីម្នាក់ទៅម្នាក់ ឬពី មួយថ្នាក់ទៅមួយថ្នាក់ ឬការបញ្ជូនឯកសារត្រឡប់ចុះឡើងច្រើនសារពេក។ ជាលទ្ធផលការអនុវត្តន៍គំរោងមិនបានស្របតាមផែនការ ថវិកា មិនបានចំណាយទាន់ពេលវេលា ហើយតម្រូវការ របស់ប្រជាពលរដ្ឋក៏មិនបានឆ្លើយតប និងដោះស្រាយទាន់ពេលវេលាផងដែរ។

**៤. ការគិតគូររយៈពេលវែងលើការប្រើប្រាស់ធនធានធម្មជាតិ**

ការគិតគូររយៈពេលវែងទៅលើការប្រើប្រាស់ធនធានធម្មជាតិមានន័យថា រាល់ការសំរេចចិត្តក្នុងការប្រើប្រាស់ធនធានធម្មជាតិ ត្រូវគិតដល់តម្លៃនៃធនធាននិរន្តភាពនៃនៃការប្រើប្រាស់ ផលប៉ះពាល់ដល់បរិស្ថាន និងកំរិតនៃភាពអាចដុះដាលឡើងវិញបាននូវធនធានធម្មជាតិទាំងនោះ។

ឧទាហរណ៍ ៖ឃុំមានបឹងតូចមួយ:

- ប្រជាពលរដ្ឋមួយចំនួនបានរកត្រីនៅក្នុងបឹងនេះដើម្បីចិញ្ចឹមជីវិត។
- ប្រជាពលរដ្ឋមួយចំនួនបានប្រើប្រាស់បឹងនេះសំរាប់ចិញ្ចឹមសត្វទានិងសត្វគោក្របី។
- ប្រជាពលរដ្ឋមួយចំនួនទៀតចង់បូមទឹកបឹងដើម្បីស្រោចស្រពស្រូវនិងចំការបន្លែ។

ប្រសិនបើការបូមទឹកសំរាប់ស្រោចស្រពច្រើនពេកបឹងនេះនឹងលែងមានត្រីនិងលែងមានទឹកសំរាប់ចិញ្ចឹមសត្វទានិងគោក្របី។ក្រុមប្រឹក្សាឃុំព្យាយាមធ្វើផែនការដើម្បីប្រើប្រាស់បឹងនេះសំរាប់បំរើឲ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋគ្រប់រូប។

រាល់ការសំរេចចិត្តដែលធានាឲ្យមាននិរន្តភាពនៃការប្រើប្រាស់ទឹកបឹងជាការសំរេចចិត្តមួយដែលល្អ និងបានគិតគូររយៈពេលវែងនៃការប្រើប្រាស់ធនធានធម្មជាតិ

៥. គ្មានអំពើពុករលួយ

គ្មានអំពើពុករលួយនៅក្នុងការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាកត្តាមួយសំខាន់ណាស់ក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ និងទទួលបាននូវទំនុកចិត្តពីប្រជាពលរដ្ឋ។ បើមានអំពើពុករលួយ នៅក្នុងការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់នោះនឹងនាំឲ្យការអនុវត្តការងារគ្មានប្រសិទ្ធភាព និងមិនត្រូវបានទទួល នូវការគោរពស្រលាញ់ពីប្រជាពលរដ្ឋឡើយ។

ឧទាហរណ៍ ៖ បើមានអំពើពុករលួយកើតឡើង នៅក្នុងការប្រើប្រាស់មូលនិធិឃុំ សង្កាត់ រវាង ក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយអ្នកដេញថ្លៃគំរោង នោះនិងធ្វើឲ្យតម្លៃគំរោងឡើងខ្ពស់ គុណភាព គំរោងអន់ និងបាត់បង់ទំនុកចិត្តពីប្រជាពលរដ្ឋ។ លើសពីនេះទៀត ប្រជាពលរដ្ឋនិងលែងចូលរួម ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងសកម្មភាពអភិវឌ្ឍន៍នានា។

៦. ការសំរេចចិត្តតាមបែបវិមជ្ឈការ

ក្រុមប្រឹក្សាឃុំ សង្កាត់រស់នៅនិងធ្វើការផ្ទាល់ជាមួយប្រជាពលរដ្ឋពួកគាត់អាចដឹងអំពី បញ្ហាតម្រូវការពិតប្រាកដរបស់ប្រជាបលរដ្ឋ និងអាចរកដំណោះណាមួយដែលមានប្រសិទ្ធភាពខ្ពស់ និងសមស្របតាមស្ថានភាពជាក់ស្តែងក្នុងឃុំ សង្កាត់របស់ខ្លួន។

ដូចនេះ ការសំរេចចិត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានការចូលរួមពីប្រជាពលរដ្ឋអាចមានប្រសិទ្ធភាពខ្ពស់ជាងអ្នកមកពីខាងក្រៅ ឬអ្នកដទៃ។

## ឆ. គណនេយ្យភាព

គណនេយ្យភាពក្នុងន័យអភិបាលកិច្ចល្អ មានន័យថាជាការអនុវត្តតួនាទី និងភារកិច្ច នៅក្នុងដំណើរការ និងអនុវត្តសេចក្តីសំរេចចិត្តហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍បានសំរេចព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសំរេចបាន និងអនុវត្ត។

គណនេយ្យភាព គឺមិនត្រឹមតែជាការទទួលខុសត្រូវចំពោះមុខអ្នកណាម្នាក់ដែលបានស្នើសុំឲ្យធ្វើអ្វីមួយនោះទេ ប៉ុន្តែជាការទទួលខុសត្រូវនូវសកម្មភាពដែលបានអនុវត្ត ចំពោះមុខអ្នកពាក់ព័ន្ធទាំងអស់ផងដែរ។

មិនមែនមានតែស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាលប៉ុណ្ណោះទេដែលត្រូវមានគណនេយ្យភាព អង្គការសង្គមស៊ីវិល និងក្រុមហ៊ុនឯកជន ក៏ត្រូវមានគណនេយ្យភាពជាសាធារណៈ ចំពោះអ្នកពាក់ព័ន្ធទាំងអស់របស់ខ្លួនផងដែរ ពិសេសចំពោះអ្នកដែលទទួលរងផលប៉ះពាល់ អំពីការសំរេចចិត្ត។

គណនេយ្យភាពរួមមាន **គណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំ** និង **គណនេយ្យភាពចំពោះមុខសាធារណជន**។

១. គណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំ

*សមាជិកម្នាក់ៗត្រូវមានគណនេយ្យភាពចំពោះមុខថ្នាក់ដឹកនាំរបស់ខ្លួនតាមលំដាប់ថ្នាក់និងអ្នកផ្តល់ធនធានថវិកា។*

ឧទាហរណ៍ មេឃុំបានស្នើឲ្យស្មៀនឃុំយករបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ ទៅឲ្យអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត។

- សកម្មភាពដែលស្មៀនឃុំយករបាយការណ៍នេះទៅឲ្យអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត គឺជាការបំពេញតួនាទី និងភារកិច្ចរបស់ស្មៀនឃុំ ។
- នៅពេលត្រលប់ដល់ឃុំហើយ ស្មៀនឃុំបានរាយការណ៍ជូនមេឃុំថាគាត់បានប្រគល់របាយការណ៍នេះ ឲ្យទៅលោក សុខ សុផល ជាមន្ត្រីរដ្ឋបាលនៃអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត នាព្រឹកថ្ងៃទី ១៨ ខែ មេសា ម្សិលមិញនេះ ព្រមទាំងបញ្ជាក់ផងដែរថា មន្ត្រីរូបនោះបានចុះហត្ថលេខានៅលើសៀវភៅបញ្ជូនលិខិត។

ស្មៀនឃុំយកសំបុត្រទៅឲ្យអង្គភាពរដ្ឋបាលមូលដ្ឋាន និងរាយការណ៍ជូនមេឃុំមានន័យថា ស្មៀនមានគណនេយ្យភាពចំពោះមេឃុំ។

**២. គណនេយ្យភាពចំពោះមុខសាធារណជន**

*មន្ត្រីសាធារណៈទាំងអស់ ត្រូវមានគណនេយ្យភាពចំពោះមុខសាធារណជន ពីព្រោះពួកគេត្រូវបានតែងតាំងឡើងដើម្បីបំរើសាធារណជន។ កាលពីមុនជារឿយៗគេបានសង្កេតឃើញថាមន្ត្រីរាជការ ត្រូវបាតែងតាំងឡើងដើម្បីដឹកនាំប្រជាពលរដ្ឋ។ ប៉ុន្តែបច្ចុប្បន្ននេះ តួនាទីរបស់មន្ត្រីរាជការ គឺផ្តោតទៅលើការផ្តល់សេវាជូនប្រជាពលរដ្ឋ។ ដូច្នេះពួកគេត្រូវមានគណនេយ្យភាពចំពោះមុខប្រជាពលរដ្ឋទូទៅ។ ដូចគ្នានេះដែរចំពោះភ្នាក់ងារឯកជនដែលផ្តល់សេវាកម្មដល់អតិថិជនរបស់ខ្លួន មិនត្រឹមតែមានគណនេយ្យភាពចំពោះអតិថិជនរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានគណនេយ្យភាពចំពោះសាធារណៈជនទូទៅផងដែរ។ ព្រោះថាការព្យាយាមផ្តល់ផលប្រយោជន៍ ឬតម្រូវចិត្តដល់អតិថិជនក្រុមណាមួយ អាចធ្វើឲ្យមានផលប៉ះពាល់ដល់ក្រុមផ្សេងទៀត ឬសាធារណៈជនទូទៅ ។*

***ឧទាហរណ៍ ៖*** *ក្រុមប្រឹក្សាឃុំ សំរេចប្រើប្រាស់ថវិកាមូលនិធិឃុំ សង្កាត់ដើម្បីសាងសង់ផ្លូវលំមួយខ្សែប្រវែង ៣ គ.ម ក្នុងភូមិមួយ។*

- *សកម្មភាពដែលក្រុមប្រឹក្សាឃុំ ធ្វើសេចក្តីសំរេចអំពីការប្រើប្រាស់មូលនិធិឃុំ និងអនុវត្តការសាងសង់ផ្លូវលំនេះ គឺជាការបំពេញតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ។*
- *បន្ទាប់ពីការសំរេច ក្រុមប្រឹក្សាឃុំ ជំរាបជូនប្រជាពលរដ្ឋ ៖*
    - *+ ដំណើរការ និងមូលហេតុនៃការធ្វើសេចក្តីសំរេចចិត្ត ក្នុងការសាងសង់ផ្លូវលំ*
    - *+ ផ្តល់ចំលើយសមរម្យ ដល់អ្នកពាក់ព័ន្ធទាំងឡាយដែលទទួលផលប៉ះពាល់ពីការសាងសង់ផ្លូវលំមួយខ្សែនោះ*

+ លទ្ធផលនៃការសាងសង់ផ្លូវលំ

ក្រុមប្រឹក្សាឃុំសំរេចប្រើប្រាស់មូលនិធិឃុំ អនុវត្តកាសាងសង់ផ្លូវលំ និងរាយការណ៍ជូនប្រជាពលរដ្ឋមានន័យថាក្រុមប្រឹក្សាឃុំ មានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ(សាធារណជន)

**ជ. ការឆ្លើយតប**

ការឆ្លើយតបក្នុងន័យអភិបាលកិច្ចល្អ មានន័យថា ជាការព្យាយាមខិតខំប្រឹងប្រែងរបស់អង្គភាព ស្ថាប័ន ដើម្បីបំរើដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់ដោយស្មើភាពគ្នា និងមិនរើសអើងនៅក្នុងក្រមខ័ណ្ឌក្នុងពេលវេលាមួយដ៏សមហេតុផល។ ការឆ្លើយតបអាចជា ៖

- ការបំពេញសេវាកម្មជូនប្រជាពលរដ្ឋតាមការស្នើសុំ
- ដំណោះស្រាយដែលស្តែងឡើងជាសកម្មភាពដើម្បីដោះស្រាយបញ្ហា ឬកាលំបាកនានា
- ការឆ្លើយបំភ្លឺអំពីមូលហេតុដែលមិនអាចឈានដល់ការធ្វើសកម្មភាពដើម្បីដោះស្រាយបញ្ហា ឬការលំបាកទាំងនោះបាន
- សំណើរសុំអន្តរាគមន៍ពីស្ថាប័ន អង្គភាពមានសមត្ថកិច្ចដើម្បីជួយដោះស្រាយបញ្ហា ឬការលំបាកទាំងនោះព្រមទាំងជំរាបអំពីសំណើសុំអន្តរាគមន៍នេះដល់ប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងបញ្ហា ឬការលំបាកទាងនោះ។

***ឧទាហរណ៍១៖*** ប្រជាពលរដ្ឋម្នាក់បានមកសុំចុះសៀវភៅអាត្រានុកូលដ្ឋានកំណើត និងសំបុត្រកំណើតឲ្យកូនរបស់ខ្លួនដែលទើបនិងកើត។ ប្រជាពលរដ្ឋរូបនេះបានមកដល់សាលាឃុំ ប៉ុន្តែគាត់មិនដឹងថាត្រូវជាមួយអ្នកណានោះទេ។ នៅពេលនោះមន្ត្រីឃុំម្នាក់បានស្វាគមន៍ និងសួរទៅកាន់ប្រជាពលរដ្ឋរូបនោះដើម្បីឲ្យដឹងថា តើគាត់ត្រូវកាសេវាអ្វីពីឃុំ។ បន្ទាប់ពីដឹងច្បាស់មន្ត្រីឃុំរូបនោះបានជំរាបដល់ប្រជាពលរដ្ឋរូបនោះភ្លាមអំពីអ្នកដែលគាត់ត្រូវជួប ព្រមទាំងនាំទៅជួបមន្ត្រីនោះតែម្តង។ មន្ត្រីឃុំ ដែលទទួលបន្ទុកបានបំពេញការងារជូនប្រជាពលរដ្ឋរូបនោះដោយទឹកចិត្តរីករាយ និងស្និតស្នាល។ ទាំងនោះគឺជាទង្វើនៃការឆ្លើយតបរបស់ឃុំចំពោះប្រជាពលរដ្ឋមូលដ្ឋានរបស់ខ្លួន។

***ឧទាហរណ៍ ២៖*** នៅភូមិ (ក)មានផ្ទុកជំងឺឆ្លងសត្វគោ ក្របី។ មេភូមិបានធ្វើលិខិតមួយមកមេឃុំដើម្បីជួយធ្វើអន្តរាគមន៍។ នៅពេលទទួលបានលិខិតនោះភ្លាមមេឃុំបានកោះប្រជុំក្រុមប្រឹក្សាឃុំវិសាមញ្ញដើម្បីដោះស្រាយបញ្ហានេះ។ បន្ទាប់ពីបានការសំរេចមេឃុំបានធ្វើសំណើទៅមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទដើម្បីជួយធ្វើអន្តរាគមន៍ចុះចាក់វ៉ាក់សាំងដល់សត្វគោ ក្របីនៃភូមិជុំវិញភូមិ (ក) និងព្យាបាលដល់សត្វគោ ក្របី នៅក្នុងភូមិ (ក)។ មេឃុំក៏បានជំរាបដល់ភូមិ(ក)ផងដែរអំពីលិខិតស្នើសុំអន្តរាគមន៍ពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីជាព័ត៌មាន។

**ចប់**